# ការចាប់ឆ្នោតរបស់វិទ្យាល័យ Kensington / វិទ្យាល័យថ្មី
# ខែមិនា ឆ្នាំ២០១៤

**តើអ្នកណាមានសិទ្ធិដាក់ពាក្យសុំចូលរៀន?**
សិស្សានុសិស្សថ្នាក់ទីប្រាំបីបច្ចុប្បន្ន ដែលមកពី សាលារបស់ក្រសួង និងសាលាក្រៅក្រសួង ត្រូវបានគេស្វាគមន៍ឲ្យដាក់ពាក្យសុំចូលរៀន។

**តើវិទ្យាល័យទាំងនេះមានលក្ខណវិនិច្ឆ័យនៃការទទួលសិស្ស ដែរឬទេ?**
គ្មានវិទ្យាល័យណាមួយ ក្នុងចំណោមវិទ្យាល័យទាំងនេះ មានការតម្រូវផ្នែកវិជ្ជាទូទៅ សម្រាប់ការទទួលសិស្សនោះទេ។ ទោះជាយ៉ាងដូច្នេះក្តី សិស្សានុសិស្សដែលដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យ Kensington CAPA នឹងតម្រូវឲ្យមានការសម្តែងសាកល្បងសម្រាប់កម្មវិធីសិល្បៈដែលផ្តល់ឲ្យនៅសាលានោះ។

**តើគេនឹងជ្រើសរើសសិស្សានុសិស្សឲ្យចូលរៀនតាមវិធីណា?**
សិស្សានុសិស្សទាំងអស់នឹងត្រូវគេជ្រើសរើសឲ្យចូលរៀនតាមការចាប់ឆ្នោតដោយកុំព្យូទ័រ។

- សម្រាប់វិទ្យាល័យ Kensington - កន្លែងនឹងទុកឲ្យសិស្សានុសិស្សដែលមានអាស័យដ្ឋាននៅក្នុងព្រំដែនដែលត្រូវទៅរៀននៅវិទ្យាល័យ Kensington។
- សម្រាប់ សាលា LINC និង សាលា U - ៥០% នៃកន្លែងសម្រាប់ថ្នាក់ទី៩ គឺសម្រាប់ទុកឲ្យសិស្សានុសិស្សដែលរស់នៅក្នុងលេខតំបន់ដូចតទៅ៖ 19120, 19121, 19122, 19123, 19124, 19125, 19130, 19132, 19133, 19134, និង 19140។ កន្លែងដែលនៅសល់ ៥០% ទៀត គឺទុកសម្រាប់សិស្សានុសិស្សដែលរស់នៅទូទាំងក្រុង។
- សម្រាប់ Building 21- ៦០% នៃកន្លែងសម្រាប់ថ្នាក់ទី៩ គឺសម្រាប់ទុកឲ្យសិស្សានុសិស្សដែលរស់នៅក្នុងលេខតំបន់ដូចតទៅ៖19120, 19121, 19122, 19123, 19124, 19125, 19130, 19132, 19133, 19134, និង 19140។ កន្លែងដែលនៅសល់ ៤០% ទៀត គឺទុកសម្រាប់សិស្សានុសិស្សដែលរស់នៅទូទាំងក្រុង។

**តើខ្ញុំនឹងទទួលការយល់ព្រមពីច្រើនកន្លែង បានដែរឬទេ?**
ទទួលបាន សិស្សអាចត្រូវគេជ្រើសរើសតាមរយៈការចាប់ឆ្នោត សម្រាប់សាលាជាច្រើន។

**ខ្ញុំបានចូលរួមក្នុងវិធីជ្រើសរើសវិទ្យាល័យ ហើយទទួលការយល់ព្រមឲ្យចូលរៀន ឬ ត្រូវបានគេដាក់ឈ្មោះខ្ញុំ នៅក្នុងបញ្ជីរង់ចាំសម្រាប់ សាលាណាមួយ។ តើការចាប់ឆ្នោតរបស់សាលា Kensington/សាលាថ្មី លប់ចោល ការយល់ព្រមនេះ ឬ កន្លែងនៅក្នុងបញ្ជីរង់ចាំ ដែរឬទេ?**
អត់ទេ។ វិធីនេះគឺដាច់ដោយឡែកពីវិធីជ្រើសរើសវិទ្យាល័យ។ បើសិនជាអ្នកទទួលការយល់ព្រមឲ្យចូលរៀន ឬដាក់ឈ្មោះនៅក្នុងបញ្ជីរង់ចាំ តាមរយៈការចាប់ឆ្នោតរបស់សាលា Kensington/សាលាថ្មី គេនឹងសុំឲ្យអ្នកធ្វើការសម្រេចចិត្តក្នុងការចុះឈ្មោះចូលរៀនចុងក្រោយបង្អស់ រវាងសាលាដែលបានយល់ព្រមទទួលអ្នកឲ្យចូលរៀន។

**តើខ្ញុំនឹងទទួលលិខិតសម្រេចចិត្តរបស់ខ្ញុំដោយវិធីណា និង នៅពេលណា?**
**គេនឹងបញ្ចេញលទ្ធផលនៃការចាប់ឆ្នោតក្នុងសប្តាហ៍នៃ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤។**

- សិស្សានុសិស្សរបស់ក្រសួងនឹងទទួលលិខិតជូនដំណឹងអំពីលទ្ធផលនៃការចាប់ឆ្នោតតាមរយៈ គេហទំព័ររបស់សិស្ស (Student Portal)។
- មាតាបិតារបស់សិស្សដែលមិនមែនជាសិស្សរបស់ក្រសួង នឹងទទួលអ៊ីមែល ជម្រាបពួកគាត់ថាលិខិតសម្រេចចិត្តមាននៅក្នុងប៉ុស្ដិ៍ការចាប់ឆ្នោតរបស់វិទ្យាល័យ Kensington/វិទ្យាល័យថ្មី។

**តើខ្ញុំអាចទទួលជំនួយក្នុងការដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យថ្មីទាំងនេះនៅ មណ្ឌលផ្តល់ជំនួយសម្រាប់មាតាបិតា និងក្រុមគ្រួសារ បានដែរឬទេ?**
អាចទទួលបាន។ ព័ត៌មានអំពីវិធីចាប់ឆ្នោតរបស់វិទ្យាល័យ Kensington/សាលាថ្មី មាននៅ មណ្ឌលផ្តល់ជំនួយសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ។ មាតាបិតា ក៏អាចប្រើកុំព្យូទ័រនៅមណ្ឌលផ្តល់ជំនួយ ដើម្បីមើលព័ត៌មានរបស់សាលា និងសួរសំណួរ បានដែរ។

**តើ សាលាទទួលសិស្សដែលមានលក្ខណសម្បត្តិពិសេស សាលាទទួលសិស្សទូទាំងក្រុង និងសាលាដែលទទួលសិស្សដោយគ្មានលក្ខណវិនិច្ឆ័យ ខុសគ្នាបែបណាដែរ?**
***សាលាទទួលសិស្សដែលមានលក្ខណសម្បត្តិពិសេស*** មានលក្ខណវិនិច្ឆ័យទទួលសិស្សដែលមានការប្រកួតប្រជែងខ្លាំង។ សិស្សានុសិស្សដែលគេទទួលឲ្យចូលរៀននៅសាលាទទួលសិស្សដែលមានលក្ខណសម្បត្តិពិសេសត្រូវមានពិន្ទុនៃការប្រឡងទូទៅ របាយការណ៍ពិន្ទុ និងវត្តមានអវត្តមាន

## ការចាប់ឆ្នោតរបស់វិទ្យាល័យ Kensington / វិទ្យាល័យថ្មី

## ខែមិនា ឆ្នាំ២០១៤

តាមការតម្រូវរបស់សាលា។ ***សាលាដែលទទួលសិស្សទូទាំងក្រុង*** មានការតម្រូវតិចតួចក្នុងការទទួលសិស្សឲ្យចូលរៀន ប៉ុន្តែក៏មានលក្ខណវិនិច្ឆ័យនៃការទទួលសិស្សដែលទាក់ទងនឹងពិន្ទុនៃការប្រឡងទូទៅ វត្តមានអវត្តមាន និងឯកសារដាក់វិន័យ ដែរ។ ***សាលាដែលទទួលសិស្សដោយគ្មានលក្ខណវិនិច្ឆ័យ*** គ្មានលក្ខណវិនិច្ឆ័យនៃការទទួលសិស្សដែលយោងទៅលើ ការសិក្សា វត្តមានអវត្តមាន ឬ អាកប្បកិរិយា ទេ។

**តើសិស្សដែលរៀននៅសាលាដែលបង្រៀនតាមវិធីផ្សេងទៀត គួរដាក់ពាក្យសុំចូលរៀន និងជ្រើសរើសចូលរៀននៅសាលាថ្មីមួយ ក្នុងចំណោមសាលាថ្មីទាំងនេះ ដែរឬទេ?**
គួរ គេជំរុញឲ្យសិស្សទាំងអស់ដាក់ពាក្យសុំចូលរៀននៅសាលាថ្មីទាំងនេះ។ គេជំរុញឲ្យសិស្សថ្នាក់ទីប្រាំបីដែលត្រូវគេបញ្ជូនឲ្យទៅសាលាផ្សេង ក្នុងពេលបច្ចុប្បន្ន ដាក់ពាក្យសុំចូលរៀន។

**តើសិស្សានុសិស្សដែលមាន IEPs ឬ ជាសិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELLs) គួរដាក់ពាក្យសុំចូលរៀន និង ជ្រើសរើសចូលរៀននៅសាលាទាំងនេះ ដែរឬទេ?**
គួរ គេជំរុញឲ្យសិស្សានុសិស្សទាំងអស់ដាក់ពាក្យសុំចូលរៀននៅសាលាថ្មីទាំងនេះ។ គេជំរុញឲ្យសិស្សានុសិស្សថ្នាក់ទីប្រាំបីបច្ចុប្បន្នដែលមាន IEPs ឬ ជាសិស្សដែលត្រូវការរៀនភាសាអង់គ្លេស ឲ្យស្វែងយល់ថែមទៀតអំពីវិធីនេះ ដោយទាក់ទងទៅអ្នកផ្ដល់ឱវាទរបស់ពួកគេ ឬ ការិយាល័យផ្ដល់ជំនួយពិសេស លេខ ២១៥-៤០០-៤១៧០។

**តើវិធីចុះឈ្មោះគឺជាអ្វី?**

- ឱកាសចុះឈ្មោះនេះគឺសម្រាប់សិស្សថ្នាក់ទីប្រាំបីទាំងអស់ ដើម្បីចុះឈ្មោះចូលថ្នាក់ទីប្រាំបួន ដែលចាប់ផ្ដើមនៅខែកញ្ញា ឆ្នាំ២០១៤។
- គេស្វាគមន៍ សិស្សានុសិស្សក្នុងក្រសួង និងក្រៅក្រសួង ឲ្យដាក់ពាក្យសុំចូលរៀន។
- វិធីដាក់ពាក្យសុំចូលរៀននឹងចាប់ផ្ដើមនៅ ថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១៤ ហើយចប់នៅម៉ោង ៥:០០ល្ងាច នៃថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។
- ការដាក់ពាក្យសុំចូលរៀនតាមការចាប់ឆ្នោតរបស់វិទ្យាល័យ Kensington/សាលាថ្មី អនុញ្ញាតឲ្យសិស្សានុសិស្សដែលចាប់អារម្មណ៍នឹងសាលាទាំងនេះ ឲ្យជ្រើសរើសសាលាតាមលេខរៀងដែលពួកគេចង់បាន។
- ការិយាល័យផ្នែក ចុះឈ្មោះ និងចាត់តាំងសិស្ស និងការិយាល័យបច្ចេកវិទ្យាព័ត៌មាន នឹងចាប់ឆ្នោតដោយគ្រឿងអេឡិចត្រូនិចសម្រាប់កន្លែងតាមចំនួនភាគរយនៃ ១) ភូមិសាស្ត្រ (លេខតំបន់ទាំង១១) និង ២) លេខតំបន់ទូទាំងក្រុង។
- គេនឹងជម្រាបក្រុមគ្រួសារអំពីលទ្ធផលនៃការចាប់ឆ្នោត។

**តើពេលវេលាសម្រាប់វិធីនេះចាប់ពីពេលណា ដល់ពេលណា?**
ថ្ងៃទី២៤ ខែមិនា៖ ចាប់ផ្ដើមការដាក់ពាក្យសុំចូលរៀននៅសាលាគំរូថ្មីបី
ថ្ងៃទី២៥ ខែមេសា៖ ឈប់ទទួលការដាក់ពាក្យសុំចូលរៀននៅសាលាគំរូថ្មីបី
សប្ដាហ៍នៃ ថ្ងៃទី៩ ខែមិថុនា៖ លិខិតជូនដំណឹងចុងក្រោយបង្អស់សម្រាប់សាលាថ្មី ផ្ញើទៅសិស្សានុសិស្ស/ក្រុមគ្រួសារ។

**???? សំណួរ ????**

សូមមើល វិបសៃ http://philasd.org/kensington-new_high_schools_lottery ដើម្បីជ្រាបពីព័ត៌មានថ្មីៗ និងព័ត៌មានបន្ថែម។ បើសិនជាលោកអ្នកមានសំណួរអ្វីអំពីវិធីនេះ សូមទាក់ទងទៅ ការិយាល័យផ្នែក ចុះឈ្មោះ និងចាត់តាំងសិស្ស លេខ ២១៥-៤០០-៥៩៨៥ ឬ អ៊ីមែលមកយើងខ្ញុំ 7schoolslottery@philasd.org។